15/11 '00 WED 12:50 FAX 855 23 218349 EMBASSY OF JAPAN

**ស្ថានទូតជប៉ុន**

ថ្ងៃទី 15 ខែ វិច្ឆិកា ឆ្នាំ 2000

# សេចក្តីប្រកាសព័ត៌មាន

បណ្តាអ្នកយកព័ត៌មានទាំងអស់ ត្រូវបានអញ្ជើញអោយចូលរួមដើម្បីយកព័ត៌មាន និង ថតរូបភាព

**ពិធីចុះហត្ថលេខាលើសារលិខិតឆ្លងជំនួយឥតសំណងរបស់ជប៉ុន**

**ជំនួយឥតសំណងសំរាប់អាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស**

ថ្ងៃទី 16 ខែ វិច្ឆិកា ឆ្នាំ 2000 វេលាម៉ោង 09:00 ព្រឹក

នៅទីស្តីការក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

ដើម្បីពង្រឹងនូវទំនាក់ទំនងមិត្តភាព និង សហប្រតិបត្តិការរវាងប្រទេសជប៉ុន និង ព្រះរាជាណាចក្រកម្ពុជា និង ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលជប៉ុនបានសំរេចផ្តល់ជំនួយឥតសំណងដែលមានទឹកប្រាក់ទាំងអស់មួយរយហាសិបប្រាំបួនលានយ៉េន (159,000,000យ៉េន ប្រហាក់ប្រហែលស្មើនឹង 1.5 លានដុល្លារអាមេរិក) ជូនដល់រាជរដ្ឋាភិបាលកម្ពុជាសំរាប់អនុវត្តនីគំរោងការ អាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស ។

សារលិខិតឆ្លងនៃកិច្ចព្រមព្រៀងនេះ នឹងត្រូវចុះហត្ថលេខានៅថ្ងៃទី 16 ខែ វិច្ឆិកា ឆ្នាំ 2000 វេលាម៉ោង 09:00 ព្រឹក នៅទីស្តីការក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រវាង ឯកឧត្តម ហោ ណាំហុង ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ និង លោក អេហ្ស៊ី យ៉ាម៉ាម៉ូតូ (Eiji YAMAMOTO) ភារធារីស្តីទីស្ថានទូតជប៉ុន ប្រចាំនៅកម្ពុជា ។

ជំនួយសំរាប់អាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្សនេះ គឺ ដើម្បីជួយគាំទ្រ និង ជួយសំរួលដល់កិច្ចខិតខំប្រឹងប្រែងធ្វើផែនការអភិវឌ្ឍន៍ធនធានមនុស្សរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ជំនួយនេះនឹងផ្តល់ជូននិស្សិតកម្ពុជានូវកាលានុវត្តភាពទទួលបានអាហារូបករណ៍ពីរដ្ឋាភិបាលជប៉ុនដើម្បីធ្វើការសិក្សាស្រាវជ្រាវនៅមហាវិទ្យាល័យជប៉ុន ។ ជំនួយនេះនឹងជួយអោយនិស្សិតកម្ពុជា 20 នាក់បានទៅសិក្សានៅមហាវិទ្យាល័យជប៉ុនចាប់ពីខែ កញ្ញា ឆ្នាំ 2001 ក្នុងមុខជំនាញសំខាន់ៗរួមមាន (1) សេដ្ឋកិច្ច (គ្រប់គ្រងហិរញ្ញវត្ថុ និង រូបិយវត្ថុ-សេដ្ឋកិច្ចអន្តរជាតិ-គ្រប់គ្រងពាណិជ្ជកម្ម) - (2) ច្បាប់ - (3) ទំនាក់ទំនងអន្តរជាតិរួមទាំងច្បាប់អន្តរជាតិ - និង (4) មុខជំនាញផ្សេងៗទៀតដែលមានសារសំខាន់សំរាប់ការអភិវឌ្ឍន៍ធនធានមនុស្ស ។

ជំនួយនេះគឺដើម្បីបន្ថែមទៅលើអាហារូបករណ៍ផ្តល់ដោយរដ្ឋាភិបាលជប៉ុន ដូចជាអាហារូបករណ៍ក្រសួងអប់រំជប៉ុន ដែលតាមរយះនេះ រដ្ឋាភិបាលជប៉ុនបានផ្តល់ជារៀងរាល់ឆ្នាំ នូវអាហារូបករណ៍ដល់និស្សិតកម្ពុជាជាង 30 នាក់ ។

❖❖❖